ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៧។

ADB ASIAN DEVELOPMENT BANK

# ប្រទេសកម្ពុជា ៖ កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុបរិយាប័ន្ន អនុកម្មវិធីទី ១

| | |
|---|---|
| **ឈ្មោះគម្រោង** | **កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុបរិយាប័ន្ន អនុកម្មវិធីទី ១** |
| **លេខគម្រោង** | 44263-013 |
| **ប្រទេស** | កម្ពុជា |
| **ស្ថានភាពគម្រោង** | កំពុងអនុវត្ត |
| **ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ** | កម្ចី<br>ជំនួយបច្ចេកទេស |
| **ប្រភពមូលនិធិ/ចំនួនទឹកប្រាក់** | **កម្ចីលេខ 3460-CAM៖ កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុបរិយាប័ន្ន អនុកម្មវិធីទី ១** |
| | ធនធានមូលធនសម្បទានធម្មតា/មូលនិធិអភិវឌ្ឍន៍អាស៊ី ៤០,០០ លានដុល្លារ |
| | **TA 9232-CAM៖ ការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុបរិយាប័ន្ន** |

| | | |
|---|---|---|
| | មូលនិធិពិសេសសម្រាប់ផ្តល់ជំនួយបច្ចេកទេស | ៦០០.០០០ ដុល្លារ |

| | |
|---|---|
| **របៀបវារៈយុទ្ធសាស្ត្រ** | កំណើនសេដ្ឋកិច្ចបរិយាប័ន្ន |
| **កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ** | អភិបាលកិច្ច និងការអភិវឌ្ឍសមត្ថភាព<br>ដំណោះស្រាយផ្នែកចំណេះដឹង<br>ការអភិវឌ្ឍវិស័យឯកជន |
| **វិស័យ/អនុវិស័យ** | ហិរញ្ញវត្ថុ - ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ |
| **សមធម៌យេនឌ័រ និង ការបញ្ជ្រាបយេនឌ័រ** | សមាសភាគយេនឌ័រមួយចំនួន |
| **ការពណ៌នា** | ផ្អែកទៅតាមភាពជោគជ័យនៃការអនុវត្តកម្មវិធីហិរញ្ញវត្ថុរបស់ ADB កន្លងមក (FSP I, II, និង III) ដោយប្រើប្រាស់វិធីសាស្ត្រដែលមានប្រសិទ្ធភាព និងបត់បែន ក្នុងការបម្លែងគោលដៅគោលនយោបាយដែលមានលក្ខណៈស្មុគស្មាញទៅជាសកម្មភាពគោលនយោបាយដែលអាចអនុវត្តបាន រដ្ឋាភិបាលបានស្នើសុំឲ្យ ADB បន្តផ្តល់ការគាំទ្រដល់វិស័យហិរញ្ញវត្ថុតាមរយៈកម្ចីសម្រាប់រៀបចំគោលនយោបាយ។ អភិក្រមកម្មវិធីដែលស្នើឡើងនេះ មានតម្លៃសរុប ៣០ លានដុល្លារ ពីមូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) ដែលមានអនុកម្មវិធីចំនួនពីរ។ អភិក្រមនេះត្រូវបានបញ្ចូលទៅក្នុងផែនការប្រតិបត្តិការប្រចាំប្រទេស (COBP) ឆ្នាំ ២០១៣-២០១៥។ ការរៀបចំអភិក្រមនេះនឹងធ្វើឡើង ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (FSDS) ២០១១-២០២០ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្រោម FSP III។ |
| **វិចារណភាពគម្រោង និងការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រទេស/** | ដោយហេតុថាវិស័យហិរញ្ញវត្ថុបានធ្វើការពង្រីកវិសាលភាពរបស់ខ្លួន និងបោះជំហានទៅរកការបង្កើតប្រព័ន្ធទីផ្សារដែលរឹងមាំ កម្មវិធីដែលស្នើឡើងនេះនឹងបន្តប្រើប្រាស់ទំនាក់ទំនងដែលបានបង្កើតរួចហើយ ជាមួយនឹងសមភាគីរដ្ឋាភិបាល និងធានាថានឹងមិនធ្វើឲ្យបាត់បង់សមិទ្ធផលដែលសម្រេចបានក្រោមកម្មវិធី FSP I, II និង III ឡើយ។ ថវិកាសរុបស្មើនឹង ៣០ |

| | |
|---|---|
| **តំបន់** | លានដុល្លារ ពីធនធានមូលនិធិពិសេសរបស់ ADB នឹងត្រូវប្រើប្រាស់ សម្រាប់អនុវត្តកម្មវិធីវិស័យហិរញ្ញវត្ថុទី ៤ (FSP IV)។ ទំហំនៃថវិកាដែលគាំទ្រកម្មវិធីនេះត្រូវបានកំណត់ផ្អែកទៅតាម (i) តម្រូវការហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍវិស័យនេះ ដូចដែលត្រូវបានកំណត់ក្នុងកំឡុងពេលរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ប្រទេស (ii) សារៈសំខាន់ដែលរដ្ឋាភិបាលផ្តល់ដល់កម្មវិធីកំណែទម្រង់ និង (iii) ចំណាយប៉ាន់ស្មានសម្រាប់រៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់រយៈពេលមធ្យម ដោយដកហិរញ្ញប្បទាន ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀតចេញ។<br><br>ផ្អែកទៅតាមកិច្ចពិគ្រោះយោបល់ដែលកំពុងមានជាមួយរដ្ឋាភិបាល ក៏ដូចជា ការណែនាំពីក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់ ADB ក្នុងកំឡុងពេលអនុវត្តកម្មវិធីមុនៗ កម្មវិធី FSP IV នឹងផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនឡើងលើ (i) ការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ជាពិសេស ការពង្រីកសេវានៅតាមតំបន់ជនបទ ជាមួយនឹងការធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុ តាមរយៈសេវាមីក្រូហិរញ្ញវត្ថុ និងការធានារ៉ាប់រងខ្នាតតូច និង (ii) ការបង្កើនតម្លាភាព និងលើកកម្ពស់អភិបាលកិច្ច ក្នុងវិស័យហិរញ្ញវត្ថុ រួមនឹងវិធានការប្រឆាំងការលាងសំអាតប្រាក់ និងការប្រយុទ្ធប្រឆាំងចំពោះការផ្តល់ហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងព័ត៌មាន។ កម្មវិធី FSP IV ក៏នឹងតាមដានវឌ្ឍនភាពលើការអភិវឌ្ឍសេវាហិរញ្ញវត្ថុដែលនៅក្មេងខ្ចីនៅឡើយ ដូចជា ទីផ្សារភាគហ៊ុន ភតិសន្យាហិរញ្ញវត្ថុ ជាមួយការកែលំអមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងគម្រោងសោធននិវត្តន៍ ដូចជា ការសន្សំប្រាក់បែបកិច្ចសន្យា។ |
| **ផលប៉ះពាល់** | បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយចីរភាព។ |

## លទ្ធផលនៃគម្រោង

| | |
|---|---|
| **សេចក្តីពិពណ៌នាអំពីលទ្ធផល** | ប្រព័ន្ធហិរញ្ញវត្ថុដែលកាន់តែពង្រីកខ្លួនធំជាងមុន មានភាពធន់ និងប្រសិទ្ធភាព ដោយមានវិសាលភាពកាន់តែធំ។ |
| **វឌ្ឍនភាពឆ្ពោះទៅសម្រេចលទ្ធផល** | |

## វឌ្ឍនភាពនៃការអនុវត្ត

| | |
|---|---|
| **សេចក្តីពិពណ៌នាអំពីទិន្នផលរបស់គម្រោង** | បង្កើនស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ តាមរយៈការបង្កើនសមត្ថភាពអភិបាល និងការបង្កើនសេវាហិរញ្ញវត្ថុថ្មីៗ<br><br>ធ្វើឲ្យកាន់តែប្រសើរនូវមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធផ្លូវច្បាប់ តាមរយៈការអនុវត្តវិធានការកាត់បន្ថយចំណាយប្រតិបត្តិការ និងចំណាយលើព័ត៌មាន។<br><br>លើកកម្ពស់អភិបាលកិច្ច និងតម្លាភាព តាមរយៈការលើកកម្ពស់វិធានការប្រឆាំងការលាងសំអាតប្រាក់ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមបទដ្ឋានអន្តរជាតិ។ |
| **ស្ថានភាពវឌ្ឍនភាពនៃការអនុវត្ត (ទិន្នផល សកម្មភាព និងបញ្ហា)** | |
| **ទីតាំងភូមិសាស្ត្រ** | |

## ប្រភេទនៃកិច្ចការពារ

| | |
|---|---|
| បរិស្ថាន | C |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | C |
| ជនជាតិដើមភាគតិច | C |

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

បរិស្ថាន

| | |
|---|---|
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | |
| ជនជាតិដើមភាគតិច | |

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| | |
|---|---|
| ក្នុងអំឡុងពេលនៃការរៀបចំគម្រោង | ជំនួយបច្ចេកទេសរៀបចំកម្មវិធី (PPTA) សម្រាប់កម្មវិធីវិស័យហិរញ្ញវត្ថុទី ៤ នេះ បានទទួលការឯកភាព ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៣។ ដោយសារតែការពន្យារពេលការអនុវត្តកម្មវិធីវិស័យហិរញ្ញវត្ថុទី ៣ (បន្តដល់ខែ មិថុនា ឆ្នាំ ២០១៤) ការអនុវត្តជំនួយបច្ចេកទេសរៀបចំកម្មវិធី (PPTA) សម្រាប់កម្មវិធីវិស័យហិរញ្ញវត្ថុទី ៤ ក៏ត្រូវបានពន្យារពេលដែរ។ បេសកកម្មនឹងចាប់ផ្តើមជ្រើសរើសក្រុមហ៊ុនផ្តល់ប្រឹក្សានៅត្រីមាសទី ៤ ឆ្នាំ ២០១៤។ |
| ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង | |

## បុគ្គលិកទទួលខុសត្រូវ

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Aoki, Hiroyuki |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកគ្រប់គ្រងវិស័យសាធារណៈ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ទីភ្នាក់ងារប្រតិបត្តិ | **ធនាគារជាតិនៃកម្ពុជា**<br>ប្រអប់សំបុត្រលេខ ២៥<br>អគារលេខ ២២-២៤ មហាវិថីព្រះនរោត្តម<br>រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ១៦ មីនា ២០១៤ |
| បេសកកម្មស្វែងរកការពិត | ២៩ មីនា ២០១៦ ដល់ ០៦ មេសា ២០១៦ |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង (MRM) | ១២ សីហា ២០១៦ |
| ការអនុម័ត | ១៧ វិច្ឆិកា ២០១៦ |

| | |
|---|---|
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ១៧ វិច្ឆិកា ២០១៦ |

កម្ចីលេខ 3460-CAM

## កាលបរិច្ឆេទសំខាន់ៗ

| អនុម័ត | កាលបរិច្ឆេទចុះហត្ថលេខា | កាលបរិច្ឆេទចូលជាធរមាន | បញ្ចប់ | | |
|---|---|---|---|---|---|
| | | | សំណៅដើម | កែសម្រួល | ជាក់ស្តែង |
| ១៧ វិច្ឆិកា ២០១៦ | ១៤ ធ្នូ ២០១៦ | ១៤ កុម្ភៈ ២០១៧ | ៣០ មិថុនា ២០១៧ | - | - |

| ផែនការហិរញ្ញប្បទាន | | ការប្រើប្រាស់កម្ចី | | | |
|---|---|---|---|---|---|
| | សរុប (គិតជាលានដុល្លារ) | កាលបរិច្ឆេទ | ADB | ផ្សេងៗ | ភាគរយពិត |
| ភាគរយពិត | ៤០,០០ | ចំនួនសរុបក្នុងកិច្ចសន្យា | | | |
| ADB | ៤០,០០ | ១៧ វិច្ឆិកា ២០១៦ | ៣៨,៦៣ | ០,០០ | ១០០% |

| | | | | | |
|---|---|---|---|---|---|
| បដិភាគ | 0,00 | ការបើកថវិកាសរុប | | | |
| សហហិរញ្ញប្បទាន | 0,00 | ១៧ វិច្ឆិកា ២០១៦ | ៣៨,៦៣ | 0,00 | ១00% |

TA 9232-CAM

## កាលបរិច្ឆេទសំខាន់ៗ

| អនុម័ត | កាលបរិច្ឆេទចុះហត្ថលេខា | កាលបរិច្ឆេទចូលជាធរមាន | បញ្ចប់ | | |
|---|---|---|---|---|---|
| | | | សំណៅដើម | កែសម្រួល | ជាក់ស្តែង |
| ១៧ វិច្ឆិកា ២០១៦ | ០៩ មីនា ២០១៧ | ០៩ មីនា ២០១៧ | ៣១ ធ្នូ ២០១៩ | - | - |

ផែនការហិរញ្ញប្បទាន/ការប្រើប្រាស់ជំនួយបច្ចេកទេស ការបើកថវិកាសរុប

| ADB | សហហិរញ្ញប្បទាន | បដិភាគ | | | | សរុប | កាលបរិច្ឆេទ | ចំនួន |
|---|---|---|---|---|---|---|---|---|
| | | រដ្ឋាភិបាល | អ្នកទទួលផល | អ្នកឧបត្ថម្ភគម្រោង | ផ្សេងៗ | | | |
| ៦០០.០០០,០០ | 0,00 | 0,00 | 0,00 | 0,00 | 0,00 | ៦០០.០០០,០០ | ១៧ វិច្ឆិកា ២០១៦ | 0,00 |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ីមិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។